00932847

E138/1/10/1/5/8/3

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 06 / 2013
ម៉ោង (Time/Heure) : 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៣

ជូនចំពោះ÷ មេធាវីការពារក្តី អៀង ធីរិទ្ធ

ពី÷ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន÷ លោក /លោកស្រីចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង, ភាគីនៃសំណុំរឿង ០០២, អង្គភាពគាំពារសាក្សី និងអ្នកជំនាញ

កម្មវត្ថុ÷ សំណើរបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សុំការបញ្ជាក់បំភ្លឺអំពីការអនុវត្តសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (ឯកសារ E138/1/10/1/5/8)

១. កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ (ឯកសារ E138/1/10/1/5/7) (សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យលក្ខខណ្ឌនៃការដោះលែង អៀង ធីរិទ្ធ)។ សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យលក្ខខណ្ឌនៃការដោះលែង អៀង ធីរិទ្ធ បានបង្គាប់ឲ្យជនជាប់ចោទ៖

ក) ជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង ឬមន្ត្រីដែលអង្គជំនុំជម្រះសាលាដំបូងចាត់តាំង មុនពេលផ្លាស់ប្តូរអាសយដ្ឋានស្នាក់នៅបច្ចុប្បន្នរបស់ជនជាប់ចោទ

ខ) មិនឱ្យចាកចេញពីព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងនោះទេ

គ) ទទួលការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្ររៀងរាល់ប្រាំមួយខែម្តង ដោយអ្នកជំនាញផ្នែកវេជ្ជសាស្ត្រដែលត្រូវបានចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូង

ឃ. ត្រូវបង្ហាញខ្លួនសម្រាប់ការត្រួតពិនិត្យផ្នែកសន្តិសុខដែលអនុវត្តដោយនគរបាលយុត្តិធម៌មួយខែម្តង ដើម្បីបញ្ជាក់ការអនុវត្តវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលបានលើកឡើងខាងលើ។ ជម្រើសផ្សេងមួយទៀត អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចថាជនជាប់ចោទត្រូវផ្តល់របាយការណ៍ប្រចាំខែ ដើម្បីបញ្ជាក់ទូវការអនុវត្តតាមវិធានការនៃការត្រួតពិនិត្យតាមផ្លូវតុលាការដែលបានរៀបរាប់ខាងលើ។

អ.ជ.ត.ក ក៏បានបង្គាប់ឱ្យប្រគល់លិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណរបស់ជនជាប់ចោទជូនទៅអ្នកអាណាព្យាបាលទូទៅដោយភ្ជាប់លក្ខខណ្ឌថា មិនត្រូវប្រើលិខិតឆ្លងដែន និងអត្តសញ្ញាណប័ណ្ណទាំងនេះ ក្នុងគោលបំណងធ្វើដំណើរទៅបរទេសដោយគ្មានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះនោះទេ ហើយនគរបាលយុត្តិធម៌ត្រូវធ្វើការត្រួតពិនិត្យជាប្រចាំខែនៅអាសយដ្ឋានដែលជនជាប់ចោទផ្តល់ជូនទៅអង្គជំនុំជម្រះដើម្បីបញ្ជាក់ថា ជនជាប់ចោទនៅតែស្នាក់នៅអាសយដ្ឋាននេះ និងមិនបានចាកចេញពីប្រទេស និងរាយការណ៍អំពីការគម្រាមកំហែងណាមួយចំពោះសុវត្ថិភាពរបស់ជនជាប់ចោទ (សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យលក្ខខណ្ឌនៃការដោះលែង អៀង ធីរិទ្ធ ផ្នែកសម្រេចសេចក្តី)។

២. កាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០១៣ មេធាវីការពារក្តី អៀង ធីរិទ្ធ បានស្នើសុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធនឹងការបកស្រាយ និងការអនុវត្តសេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ (ឯកសារ E138/1/10/1/5/8) ("សំណើរបស់មេធាវីការពារក្តី")។ មេធាវីការពារក្តីលើកឡើងថា ព័ត៌មានលម្អិតស្តីពីរបៀបអនុវត្តប្រព័ន្ធនៃការត្រួតពិនិត្យតាមផ្លូវតុលាការនេះ គឺជាការចាំបាច់ដើម្បីបញ្ចៀសការកំហិតបន្ថែមទៀតទៅលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទទាក់ទងនឹងសិទ្ធិមានឯកជនភាព និងសេរីភាព។ សំណើរបស់មេធាវីការពារក្តីបានស្នើសុំការបញ្ជាក់បំភ្លឺពាក់ព័ន្ធនឹង៖

ក. តើជនជាប់ចោទត្រូវជូនដំណឹងទៅអ្នកណា ហើយត្រូវជូនដំណឹងដោយវិធីណា?

00932849

ខ. លក្ខណៈនៃការត្រួតពិនិត្យផ្នែកវេជ្ជសាស្រ្តរៀងរាល់ប្រាំមួយខែម្តង អត្តសញ្ញាណ និងតួនាទីរបស់មន្រ្តីដែលត្រូវបានជ្រើសតាំងដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីបំពេញការងារត្រួតពិនិត្យផ្នែកវេជ្ជសាស្រ្តរៀងរាល់ប្រាំមួយខែម្តង ទីកន្លែង កាលបរិច្ឆេទ និងពេលវេលា និងប្រសិនបើមាន ភាគីផ្សេងៗនៃកិច្ចដំណើរការនីតិវិធីដែលអាចត្រូវបានផ្តល់របាយការណ៍ទាំងនេះ ព្រមទាំងនីតិវិធីជាធរមាន នៅក្នុងករណីដែលស្ថានភាពវេជ្ជសាស្រ្តដែលពុំត្រូវបានកំណត់ឃើញកាលពីពេលមុន ត្រូវបានរកឃើញ ក្នុងអំឡុងពេលត្រួតពិនិត្យផ្នែកវេជ្ជសាស្រ្តទាំងនេះ ឬប្រសិនបើជនជាប់ចោទ អៀង ធីរិទ្ធ ធ្លាក់ខ្លួនឈឺនៅថ្ងៃខាងមុខ ឬត្រូវការការយកចិត្តទុកដាក់ និងការថែទាំវេជ្ជសាស្រ្តបន្ថែមទៀតក្នុងទម្រង់ណាមួយ។

គ. អត្តសញ្ញាណ និងតួនាទីរបស់អ្នកដែលទទួលបានការចាត់តាំងដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីពិនិត្យសន្តិសុខ ប្រភេទនៃការត្រួតពិនិត្យសន្តិសុខ ទីតាំង កាលបរិច្ឆេទ និងពេលវេលានៃការត្រួតពិនិត្យ និងអត្តសញ្ញាណអ្នកដែលនឹងត្រូវពិនិត្យលើបញ្ហាទាំងនេះ។ មេធាវីការពារក្តីលើកឡើងថា ពុំមានភាពច្បាស់លាស់ថាតើអង្គជំនុំជម្រះតុលាការកំពូលចង់កំណត់ការត្រួតពិនិត្យពីរដាច់ដោយឡែកពីគ្នា ដែលមួយគឺជាការត្រួតពិនិត្យសន្តិសុខដែលត្រូវធ្វើដោយនគរបាលយុត្តិធម៌ និងមួយទៀតដោយជនជាប់ចោទ តាមរយៈអាណាព្យាបាលគាត់ ឬមួយថា អង្គជំនុំជម្រះតុលាការកំពូលចង់ឱ្យត្រួតពិនិត្យទាំងអស់រួមគ្នា ដោយបញ្ចូលទៅក្នុងការត្រួតពិនិត្យសកម្មភាព និងការចងក្រងរបាយការណ៍ប្រចាំខែតែមួយ។ មេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ ក៏ចោទប្រកាន់អំពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងវិធានការផ្សេងៗដែល អ.ជ.ត.ក បានកំណត់ និងការត្រួតជាន់គ្នា ដែលអាចមានចំពោះតួនាទីនានាពាក់ព័ន្ធនឹងកាតព្វកិច្ចដូចគ្នារបស់អាជ្ញាធរកម្ពុជាក្នុងការធានាសុវត្ថិភាពដល់ជនជាប់ចោទ។

ឃ. នីតិវិធីដែលត្រូវអនុវត្តដើម្បីទទួលបានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះសាលាដំបូង នៅក្នុងករណីដែលជនជាប់ចោទមានបំណងចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់ហេតុផលវេជ្ជសាស្រ្ត ដោយសារជនជាប់ចោទមានស្ថានភាពទ្រុឌទ្រោម ហើយបញ្ហាអាសន្នផ្នែកសុខភាព គឺជាបញ្ហាបន្ទាន់មួយ។

ង. ដោយពិនិត្យទៅលើផលអវិជ្ជមានដែលអាចមាននៃការរំលោភលើលក្ខខណ្ឌទាំងនេះ

ចំពោះសិទ្ធិរបស់ជនជាប់ចោទនោះ មេធាវីស្នើសុំការបញ្ជាក់បំភ្លឺអំពីនីតិវិធីដែលត្រូវអនុវត្ត ប្រសិនបើជនជាប់ចោទពុំអាចបំពេញបានទៅតាមពេលវេលាដែលអង្គជំនុំជម្រះបានកំណត់ ដោយសារជនជាប់ចោទមានបញ្ហាសុខភាព ឬពុំមានសមត្ថភាពផ្នែកបញ្ញាស្មារតី ឬរំលោភទៅលើលក្ខខណ្ឌទាំងនេះ។

៣. កាលពីថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ ដោយបានសម្រេចថា អង្គជំនុំជម្រះគ្មានយុត្តាធិការដើម្បីបញ្ជាក់បំភ្លឺ ឬបង្ហាញយោបល់លើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលឡើយ។ ហេតុដូច្នេះ សំណើនេះត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះតុលាការកំពូលដើម្បីស្នើសុំការបញ្ជាក់បំភ្លឺ និងការណែនាំបន្ថែម។ យ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់អំពីវិធានការដាក់លាក់ដែលខ្លួនរំពឹងថាអនុវត្តទាក់ទងនឹងបញ្ហាពាក់ព័ន្ធនឹង (១) ការជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន និង/ឬ ការធ្វើដំណើរទៅបរទេស (២) ពេលវេលា និងការតែងតាំងវេជ្ជបណ្ឌិតផ្នែកជំងឺផ្លូវចិត្តសម្រាប់ការត្រួតពិនិត្យវេជ្ជសាស្ត្របន្ថែម និង (៣) របាយការណ៍ស្តីពីការអនុវត្តតាមការបង្គាប់។ អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំការបញ្ជាក់បំភ្លឺជាក់លាក់ស្តីពី (១) វិសាលភាពនៃការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ និងអ្នកទទួលខុសត្រូវចំពោះការចំណាយលើការត្រួតពិនិត្យទាំងនេះ និង (២) បញ្ហាពាក់ព័ន្ធនឹងផលវិបាកចំពោះជនជាប់ចោទក្នុងការមិនអនុវត្តតាមលក្ខខណ្ឌដែលបានដាក់តាមផ្លូវតុលាការ។

៤. នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ នៅក្នុងសេចក្តីសម្រេចលើសំណើរបស់អង្គជំនុំជម្រះសាលាដំបូង និងមេធាវីការពារក្តី អៀង ធីរិទ្ធ សុំការណែនាំ និងការបញ្ជាក់បំភ្លឺ (ឯកសារ E138/1/10/1/5/8/2) ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំការបញ្ជាក់បំភ្លឺ") អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជូនសំណើនេះត្រឡប់មកអង្គជំនុំជម្រះសាលាដំបូងវិញ ដោយបង្គាប់ឲ្យអនុវត្តសេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយឥតបង្អង់ឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលទទួលយកសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលស្នើសុំការបំភ្លឺទាក់ទងទៅនឹងបញ្ហាអង្គច្បាប់។

៥. ចំពោះចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ការត្រួតពិនិត្យផ្នែកវេជ្ជសាស្ត្រ "មានគោលដៅបញ្ជាក់ថាតើ ស្ថានភាពសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើង ឬថយចុះ ព្រមទាំងធ្វើការវាយតម្លៃពីតម្រូវការក្នុងការព្យាបាល" និងបានបញ្ជាក់ថា "នៅពេលដែលអាចមានការ

ដាក់ទណ្ឌកម្មដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ ការអនុវត្តតម្រូវឱ្យមានការវាយតម្លៃលើបញ្ហាស្តីពីការទទួលខុសត្រូវ ក៏ដូចជាភាពចាំបាច់ និងភាពសមស្របទៅតាមកាលៈទេសៈនីមួយៗ។ យោងតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង សូម្បីតែគ្មានធាតុអត្តនោម័តក្តី [...] វិធានការរដ្ឋបាលអាចត្រូវបានបង្គាប់ឡើង ដើម្បីបញ្ឈប់ការជ្រៀតជ្រែកនេះ ឬរារាំងមិនឱ្យកើតឡើងសារជាថ្មី"[1]។

៦. នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងអំពីវិធានការដូចខាងក្រោមនេះ ក្នុងការអនុវត្តសេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការអនុវត្ត និងសេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការ និងការបញ្ជាក់បំភ្លឺ៖

*i. ការជូនដំណឹងអំពីការផ្លាស់ប្តូរអាសយដ្ឋាន និង/ឬការធ្វើដំណើរទៅបរទេស*

(ក) ជនជាប់ចោទ ឬអាណាព្យាបាលត្រូវជូនដំណឹងដល់ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងយ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃ មុនពេលធ្វើការផ្លាស់ប្តូរអាសយដ្ឋាន និងយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មុនការស្នើសុំធ្វើដំណើរទៅបរទេស។ ក្នុងករណីដែលតម្រូវឱ្យបញ្ជូនជនជាប់ចោទទៅសង្គ្រោះបន្ទាន់ដើម្បីព្យាបាលនៅបរទេស ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងត្រូវទទួលបាននូវការជូនដំណឹងនេះឱ្យបានឆាប់រហ័សបំផុតតាមការជាក់ស្តែង និង នៅមុនពេលធ្វើការបញ្ជូននេះ ។

(ខ) អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ពីការទទួលបាននូវការជូនដំណឹងពីការផ្លាស់ប្តូរអាសយដ្ឋានជនជាប់ចោទ ឬ ពីការយល់ព្រមឱ្យធ្វើដំណើរទៅបរទេស តាមការជាក់ស្តែង។

*ii. ការពិនិត្យសុខភាព*

(ក) អង្គជំនុំជម្រះសាលាដំបូងនឹងតែងតាំងអ្នកជំនាញផ្នែកវិកលវិទ្យាមួយរូប ដើម្បីធ្វើការវាយតម្លៃឡើងវិញឱ្យបានទៀតទាត់លើមុខងារសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ តាមសេចក្តីបង្គាប់នៅក្នុងកថាខណ្ឌ ៦៧-៦៨ នៃសេចក្តីសម្រេចរបស់ អ.ជ.ត.ក។

[1] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើសំណើសុំការបញ្ជាក់បំភ្លឺ កថាខណ្ឌ ១១ និង ១៥។

(ខ) គោលបំណងនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រនេះ ត្រូវបានកំណត់ត្រឹមការបញ្ជាក់ថាតើស្ថានភាពសតិបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ មានភាពប្រសើរឡើង ឬថយចុះ ព្រមទាំងធ្វើការវាយតម្លៃពីតម្រូវការក្នុងការព្យាបាលសមស្របណាមួយដែលអាចធ្វើបាន។

(គ) ការវាយតម្លៃឡើងវិញជាទៀងទាត់លើកដំបូង នឹងត្រូវបានកំណត់កាលបរិច្ឆេទនៅក្នុងខែ កញ្ញា ឆ្នាំ ២០១៣។ ដូច្នេះ ការវាយតម្លៃឡើងវិញនេះ នឹងត្រូវបង្គាប់ឡើងជារៀងរាល់០៦ (ប្រាំមួយ) ខែ អនុលោមតាម សេចក្តីសម្រេចរបស់ អ.ជ.ត.ក ស្តីពីការអនុវត្ត។

(ឃ) ព័ត៌មានលម្អិតបន្ថែមពាក់ព័ន្ធនឹងអត្តសញ្ញាណនៃអ្នកជំនាញផ្នែកវិកលវិទ្យា និងរយៈពេលនៃការវាយតម្លៃឡើងវិញនេះត្រូវធ្វើការជូនដំណឹងនៅក្នុងពេលសមស្រប នាពេលក្រោយ។

(ង) របាយការណ៍ទៀតទាត់ទាំងនេះ ត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

*iii. របាយការណ៍ស្តីពីការគោរពតាមលក្ខខណ្ឌនានា*

ប្រសិនបើជនជាប់ចោទ តាមរយៈអាណាព្យាបាលទូទៅរបស់គាត់ផ្តល់ការបញ្ជាក់ជារៀងរាល់ខែនៅថ្ងៃចុងក្រោយនៃថ្ងៃធ្វើការក្នុងខែនីមួយៗ (គិតចាប់ពីថ្ងៃ ពុធ ទី ៣១ ខែ កក្កដា ឆ្នាំ ២០១៣) ជូនដល់អង្គជំនុំជម្រះសាលាដំបូងថា អ្នកស្រីកំពុងស្ថិតនៅក្នុងអាសយដ្ឋានបច្ចុប្បន្នរបស់គាត់ និងរាយការណ៍អំពីការគំរាមកំហែងណាមួយលើសន្តិសុខរបស់គាត់ប្រសិនបើមាននោះ អង្គជំនុំជម្រះសាលាដំបូងពុំតម្រូវឱ្យជនជាប់ចោទ ឬនគរបាលយុត្តិធម៌ធ្វើការត្រួតពិនិត្យបញ្ហាសន្តិសុខបន្ថែមណាមួយឡើយ។

៧. នេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើរបស់មេធាវីការពារក្តី ឯកសារ E138/1/10/1/5/8។